# ការសង្កេតទូទៅលើរឿងព្រេង«នាងកែវប្រាំពីរពណ៌»

នៅស្រុកខ្មែរមានរឿងព្រេងជាច្រើនដែលមានភ្ជាប់នឹងទីតាំងភូមិសាស្ត្រ។ យើងពុំអាចដឹងដែរថារឿងទាំងនោះកើតឡើងពីពេលណាឱ្យប្រាកដ ឬរឿងនោះជារឿងពិតយ៉ាងណានោះទេ ត្បិតជួនកាលរឿងទាំងនោះមានលាយសាច់រឿងដែលជាអព្ភូតហេតុពិសេសលើសភាពជាមនុស្សអាចធ្វើបាន។ នៅខេត្តសៀមរាប យើងអាចរកមនុស្សចាស់ៗដែលចេះរឿងនិទានតៗគ្នាបានយ៉ាងងាយ ដែលពួកគាត់អាចពណ៌នាយ៉ាងរត់មាត់ផងនោះគឺរឿងនាងកែវប្រាំពីរពណ៌ ដែលសាច់រឿងនេះមានភ្ជាប់នឹងភូមិសាស្ត្រជាក់ស្តែងចាប់ពីបារាយណ៍ទឹកថ្លារហូតដល់ទន្លេសាប។ ទោះជារឿងនេះមានព្រឹត្តិការណ៍ជាប់នឹងបារាយណ៍មកខាងត្បូងជាប់នឹងទន្លេសាបក៏មែនពិត តែអ្នករស់នៅឆ្ងាយពីបារាយណ៍គួរសមដែរនោះក៏គង់តែស្គាល់រឿងដ៏ល្បីល្បាញនេះ។

សាច់រឿងនេះមានបរិយាយលំអិតក្នុងនិក្ខេបបទរបស់លោក សូ ឆេង និង ឡាំ សុភ័ក្ត្រ។[1] ក្រោយមកមានការសិក្សាបន្ថែមពីលោក សាង សំណាង ដោយផ្តោតសំខាន់ទៅលើប្រាសាទវត្តចេតិយ។[2] ទីនេះខ្ញុំសូមតំណាលយ៉ាងខ្លីថា៖

ដើមឡើយនៅមានស្តេចមួយអង្គសោយរាជ្យនៅអង្គរមានបុត្រីមានពណ៌រូបឆោមល្អជាច់គេ ដោយសារព្រះនាងមានព្រះកាយភ្លឺ៧ពណ៌។ ពេលមួយព្រះនាងអផ្សុកក្នុងហឫទ័យសុំបីតាទៅក្រសាលព្រៃ មានម្នាង សេនា អមាត្យកក្រើកក្រេងអមដំណើរ ក៏ប្រទះឃើញពងមួយ ហើយស្រលាញ់ពងនោះណាស់រួចក៏យកលាក់ទុកក្នុងដំណាក់។ ពងនោះញាស់ជាកូនក្រពើតូចមួយ ព្រះនាងយកកូនក្រពើនោះទៅចិញ្ចឹមក្នុងបារាយណ៍ ហើយឱ្យចំណីជាប្រចាំ។ ក្រពើមានឈ្មោះថា អាធន។ វាស្រឡាញ់ព្រះនាងជាម្ចាស់វាខ្លាំងណាស់។

[1] សូ ឆេង និង ឡាំ សុភ័ក្ត្រ ១៩៩៧: ៥៦-៦២។ សាច់រឿងក្នុងស្នាដៃនេះ គេយកមកបន្ថែមគំនូរពណ៌ សូមអាន Marui et al. ២០០១។

[2] សាង សំណាង ២០០២: ៧-១៣។

អត្ថបទដោយ៖ អ៊ូ គង្គា

ថ្ងៃមួយ វាឮដំណឹងថាស្ដេចក្រុងចិនមក ដណ្ដឹងព្រះនាងលើកបណ្ដាការការពីក្រុងចិនមកហើយ។ ថ្ងៃនោះឯង វាបញ្ឆិះព្រះនាងលេងពេញក្នុងបាពយណ៍មួយសន្ទុះធំ។ រួចទៅក្រពើអាធនលេបព្រះនាងរត់ពីបាពយណ៍ធ្លាក់មកស្ទឹងកំបុត ជិតព្រៃកទាល់ ហើយមកសម្ងំខ្លួននៅម្ដុំអន្ទង់សាក្បែរគោកតាសួស។ ទើបតាដោកជាមេទ័ពខ្លាំងពូកែចាប់ក្រពើនោះបានហើយវះពោះក្រពើសង្រ្គោះព្រះនាង តែព្រះនាងសុគតទៅហើយ។ ដោយសារព្រះនាងសុគតដោយមិនប្រក្រតី (តៃហោង) ព្រះរាជបញ្ជាមកពីវាំងថាឱ្យរកកោះទីស្ថានស្ងាត់ណាមួយធ្វើបុណ្យ។ ហែមកដល់ព្រៃស្អុយក៏ធុំក្លិនស្អុយ។ ហែមកដល់ព្រៃដង្ហើម ព្រះនាងនៅដង្ហើមតិចៗ។ មកដល់ព្រៃផ្ដៅក៏ដាច់ខ្សែ គេឈប់បោចផ្ដៅចង់ស្នែងព្រះនាងហែមកដល់ម្ដុំវត្តចេតិយ។ បន្ទាប់មក ព្រះបីតាកសាងប្រាសាទបញ្ចុះព្រះនាងនៅទីនេះ ហើយឱ្យមេទ័ពតាដោកនៅចាំយាមនៅទីនោះ។ ឯក្រពើអាធនត្រូវគេវះធ្វើទង់ក្រពើរហូតមកដល់សព្វថ្ងៃ។

ទីតាំងរៀបរាប់ក្នុងសាច់រឿងមានពិតនៅលើភូមិសាស្ត្រជាក់ស្ដែង ដែលសព្វថ្ងៃស្ថិតនៅចាប់ពីបាពយណ៍ទឹកថ្លាទៅត្បូង។ ការនេះពុំខុសអ្វីពីរឿងព្រេងដទៃទៀត ដែលសាច់រឿងមានភ្ជាប់នឹងទីតាំងជាក់ស្ដែង ប៉ុន្តែគួរកត់សម្គាល់ថា រឿងនេះមានភ្ជាប់នឹងទីតាំងច្រើនដែលដំណាក់កាលនីមួយៗកើតឡើងនៅតាមទីតាំងភូមិសាស្ត្រនីមួយៗដែរ ហើយទីតាំងទាំងនោះសឹងមានស្លាកស្នាមជាប្រាសាទបុរាណ (សូមមើលផែនទី)។

ក្នុងសាច់រឿងទីតាំងដែលសំខាន់ជាងគេគឺ នៅវត្តចេតិយជាទីដែលគេបញ្ចុះព្រះនាងនៅទីនោះ។ នៅវត្តចេតិយសាងសង់នៅលើទួលជារចនាសម្ព័ន្ធរបស់ប្រាសាទបុរាណ។ ប្រាសាទសាងសង់ក្នុងរវាងស.វទី១០ ក្នុងរចនាបថបាខែង។[៣] យ៉ាងនេះក្ដី នៅទីនោះមានបំណែកសសរពេជ្រដែលមានទម្រង់សិល្បៈបែបសម័យមុនអង្គរដែរ។ បច្ចុប្បន្នអ្នកស្រុកបូកស៊ីម៉ង់ត៍លាបពីលើប្រាសាទឥដ្ឋដែលខូចខាតដោយកន្ទ្វេង (រូបលេខ១)។ នៅពីខាងកើតមានព្រះវិហារដែលនេះជាទំនៀមទូទៅក្នុងសម័យកណ្ដាល។ ប្រាសាទនេះក៏មិនខុសពី

---

[៣] សូមអានស្នាដៃលំអិតរបស់ សាង សំណាង ២០០២។

ប្រាសាទមួយចំនួនធំក្នុងស្រុកខ្មែរ ដែលត្រូវគេកែប្រែទៅជាចេតិយក្នុងសម័យកណ្ដាល។[៨] ករណីនេះ យើងក៏អាចលើកយកមកធ្វើជាឧទាហរណ៍មួយក្នុងការរួមចំណែកសិក្សាពន្យល់លើន័យ ប្រាសាទ ឬផ្នូរ ដូចដែលអ្នកប្រាជ្ញធំៗធ្លាប់វែកញែកកន្លងមក។[៩]

បច្ចុប្បន្នព្រះចៅអធិការឱ្យគេយកស៊ីម៉ង់ត៍ ធ្វើចេញជាសាច់រឿងនាងកែវព្រះពីរពណ៌ ពីដើមដល់ចប់នៅតាមផ្លូវចូលវត្ត ប៉ុន្តែរលុះអស់ខ្លះដោយសារគុណភាពស៊ីម៉ង់ត៍ (រូបលេខ ២-៤)។ នៅផ្លូវចូលពីខាងកើតមានខ្ទមអ្នកតាឈ្មោះតាដោក ដែលមានមានរៀបរាប់ក្នុងសាច់រឿងពីខាងលើ។ តាដោមជាអ្នកតាមួយយ៉ាងសំខាន់របស់វត្ត។ កាលណាមានរៀបចំកិច្ចពិធីនានា គេត្រូវមករៀបចំថ្វាយអ្នកតានេះមុនគេ។ ពេលនោះជាពេលបុណ្យទេសន៍មហាជាតក គេជួលក្រុមឆៃយ៉ាំសម្រាប់ហែនគរកណ្ឌ។ មុននឹងឆៃយ៉ាំដឹកមុខហែនគរកណ្ឌ គេឱ្យក្រុមក្មេងមកលេងរាំថ្វាយតាដោកជាមុនសិន (រូបលេខ៥)។

កាលនោះជាការចែជន្យប៉ុណ្ណោះ មានស្ត្រីម្នាក់ប្រាប់ខ្ញុំថាគាត់មានរូបទំឈ្មោះ នាងក្រពុំឈូក។ ដូចដែលយើងដឹងខ្លះហើយ រឿងនេះល្បីល្បាញខ្លាំង នៅវត្តសសរ១០០មានទាំងចេតិយផង។ តាមពិតរឿងនាងក្រពុំឈូក និងរឿងនាងកែវប្រាំពីរពណ៌មានភាពស្រដៀងគ្នាច្រើន ពិសេសគឺត្រូវក្រពើលេបដូចគ្នា។ ម្ល៉ោះហើយ ខ្ញុំយល់ថាស្ត្រីរូបនោះទំនងជាស្គាល់រឿងទាំង២ហើយយកមកបញ្ចូលគ្នាតែមួយ ពោលគឺយករឿងពីមជ្ឈដ្ឋានផ្សេងមកបញ្ចូលនឹងរឿងនេះ។ ក្រោយមកទៀត គេធ្វើរូបសំណាក់មនុស្សស្រីជិះក្រពើនៅចំពីមុខប្រាសាទ(រូបលេខ៦)។ រូបនេះល្មមនឹងឱ្យអ្នកសិក្សាប្រវត្តិសិល្បៈដែលមិនធ្លាប់ដឹងរឿងព្រេងនាងកែវប្រាំពីរពណ៌សន្មត់ថាជារឿងទេវកថាដែលខ្មែរស្គាល់ពីឥណ្ឌាផងក៏មិនដឹង។

[៨] Thompson 2004។

[៩] Cœdès ២០០៧។

នាងគង្ហាមានជំនិះជាសត្វក្រពើ ហើយនៅសម័យបុរាណផងនោះ ខ្មែរមិនមែនស្គាល់ទេវីនេះលំៗឡើយ ដោយមានបង្ហាញតាមប្រាសាទ និងសិលាចារឹកជាច្រើន។[៦]

តាមការសង្កេតទូទៅនៃនិក្ខេបបទរបស់លោក សូរ ឆេង និងឡាំ សុក័ក្ត្រ ប្រាសាទនៅកណ្ដាលបារាយណ៍តែងហៅឈ្មោះថាមេបុណ្យ និងមានរឿងទាក់ទងនឹងក្រពើឈ្មោះ «អាធន»។[៧] ត្រង់នេះគួរកត់សម្គាល់បន្ថែមថា «ទឹក,ក្រពើ,មនុស្សស្រី» ហាក់មានទំនាក់ទំនងគ្នាខ្លាំង។ នៅវត្តមហាលាភ ស្រុកកោះសុទិនជាដើមក៏មានទាក់ទងនឹងរឿងព្រេង «ក្រពើនាងឱវ៉ែ» ហើយវត្តនោះនៅជាប់នឹងមាត់ទន្លេតូច។ រឿងព្រេង«នាងក្រពុំឈូក»ជាដើមសឹងតែជាប់ពាក់ព័ន្ធរវាងមនុស្សស្រី ក្រពើ និងទឹក។ មិនតែប៉ុណ្ណោះ អ្នកស្រុកនៅជុំវិញបារាយណ៍ទឹកថ្លាមានតំណមបញ្ចៀសមិននិយាយពាក្យ«ក្រពើ»ជាដើម នៅពេលគេទៅរកត្រីក្នុងបារាយណ៍ ត្បិតគេជឿថាក្នុងបារាយណ៍មានក្រពើថែរក្សាទីនោះ។

ជាចុងក្រោយ ខ្ញុំសូមបញ្ជាក់ម្ដងទៀតថាខាងលើនេះជាការសង្កេតទូទៅប៉ុណ្ណោះ។ យើងអាចរកឃើញរឿងព្រេងជាច្រើនទៀតដែលគេយកភូមិសាស្ត្រដាក់ស្ដែងមកពន្យល់ភ្ជាប់នឹងសាច់រឿង។ សាច់រឿងទាំងនោះអាចមានលាយឡំជាមួយទេវកថាផងក៏បាន ដោយគេយកលក្ខណៈពិសេសរបស់តួអង្គមកលាយឡំផ្សំបញ្ចូលបង្កើតជាសាច់រឿងថ្មី។ ឬអាចជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រកើតឡើងក្នុងពេលណាមួយដែលមនុស្សចាំតៗគ្នា ហើយបញ្ចេញបញ្ចូលសាច់រឿងបន្ថែម៕

[៦] សូមអាន អ៊ូ គង្ហា ២០១៣។

[៧] សូ ឆេង និង ឡាំ សុក័ក្ត្រ ១៩៩៧ : ៤៣។

អត្ថបទដោយ៖ អ៊ូ គង្ហា

## *ឯកសារពិគ្រោះ*

*សាង សំណាង*

២០០២. *ប្រាសាទវត្តចេតិយ*, និក្ខេបបទបុរាណវិទ្យា។

*សូ ឆេង និង ឡាំ សុភ័ក្រ្ត*

១៩៩៧. *ពិចារណាលើរឿងព្រេងដែលនិទានអំពីប្រាសាទ*, និក្ខេបបទបុរាណវិទ្យា។

*អ៊ូ គង្គា*

២០១៣. *ព្រះគង្គា*, គ្រឹះស្ថានបោះពុម្ពផ្សាយនគរវត្ត, ភ្នំពេញ។

Cœdès Gorges,

២០០៧, «អង្គរវត្តជាប្រាសាទ ឬផ្នូរ?» *ខ្មែរ័យ*, លេខ៨, បកប្រែដោយ អាំង ជូលាន, ទំ.២៨១-២៨៩

Marui, Masako, ឯក ប៊ុនថា និង សុខ ជួក

២០០១, *ព្រះនាងកេរប្រាំពីរពណ៌៖ រឿងព្រេងខ្មែរ ប្រវត្តិសាស្រ្ត បូជនីយដ្ឋាន និងជីវភាពរស់នៅ*, បោះពុម្ពលើកទី២, JSRC, ភ្នំពេញ

Pottier, Christophe.

1999, *Carte archéologique de la region d'Angkor-Zone Sud*, Doctoral Dissertation, Université Paris III Sorbonne Nouvelle.

Thompson, Ashley.

2004, 'Pilgrims to Angkor: A Buddhist `Cosmopolis´ in Southeast Asia?'. *Bulletin of Students of the Department of Archaeology.3,* Royal University of Fine Arts, Phnom Penh, p.88-119.

KHMER CIVILIZATION




ទីតាំងមានរៀបរាប់ក្នុងសាច់រឿង (ទិន្នន័យៈ Pottier 1999)

អត្ថបទដោយៈ អ៊ូ គង្គា



រូបលេខ១៖ ប្រាសាទវត្តចេតិយ



រូបលេខ២៖ រៀបរាប់ផ្តើមរឿង



រូបលេខ៣៖ ព្រះនាងកែវប្រាំពីរពណ៌ប្រទះពងក្រពើ



រូបលេខ៤៖ ក្រពើអាធនបញ្ជិះព្រះនាងកែវប្រាំពីរពណ៌



រូបលេខ៥៖ រោងតាដោក



រូបលេខ៦៖ ចម្លាក់នាងកែវប្រាំពីរពណ៌គង់លើក្រពើ